**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល
# ស្តីពី
# កម្មវិធីចាក់វ៉ាក់សាំងកូវីដ-១៩ ជូនបងប្អូនកម្មករប្រមូលសម្រាមនៅរាជធានីភ្នំពេញ

យោងតាមអនុសាសន៍ណែនាំ និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ការចាក់វ៉ាក់សាំងកូវីដ-១៩ "ស៊ីណូហ្វាម (Sinopharm Beijing Institute of Biological Products)" ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់សាធារណរដ្ឋប្រជាមានិតចិន ត្រូវបានអនុញ្ញាតឱ្យបន្តចាក់ជូនដល់បងប្អូនដែលជាកម្មករប្រមូលសម្រាមនៅរាជធានីភ្នំពេញ បន្ថែមលើក្រុមមនុស្សដែលជាបុគ្គលិកសុខាភិបាល កងកម្លាំងប៉ូលីសជាតិ និងអាជ្ញាធរជួរមុខ ដូចជាគណៈអភិបាលខេត្ត គណៈអភិបាលក្រុង/ស្រុក/ខណ្ឌ គណៈកម្មការភូមិ-ឃុំ-សង្កាត់

ក្រសួងសុខាភិបាល សូមអញ្ជើញបងប្អូនជាកម្មករប្រមូលសម្រាមនៅរាជធានីភ្នំពេញ ដែលមានអាយុពី ១៨ឆ្នាំ ដល់ ៥៩ឆ្នាំ ទៅទទួលការចាក់វ៉ាក់សាំងដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ នៅតាមទីតាំងដូចខាងក្រោមនេះ៖

| | |
|---|---|
| ១). មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ | ២). មន្ទីរពេទ្យបង្អែកព្រែកព្នៅ |
| ៣). មន្ទីរពេទ្យបង្អែកច្បារអំពៅ | ៤). មន្ទីរពេទ្យបង្អែកដង្កោ |
| ៥). មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិន សែនសុខ | ៦). មន្ទីរពេទ្យបង្អែកចតុមុខ |
| ៧). មន្ទីរពេទ្យបង្អែកសម្តេចឪ សម្តេចម៉ែ | ៨). មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង។ |

បន្ថែមលើនេះ ដោយក្រសួងបានពង្រីកទីតាំងចាក់វ៉ាក់សាំងដល់គ្រប់រាជធានី-ខេត្តទាំង២៥ ហើយនោះ និងដើម្បីជម្រុញការចាក់វ៉ាក់សាំងឱ្យមានសៃលភាពកាន់តែទូលំទូលាយ ទីតាំងចាក់វ៉ាក់សាំងទាំងអស់ដែលមានការអនុញ្ញាតពីក្រសួងរួចហើយនោះ ត្រូវបន្តការងារចាក់វ៉ាក់សាំងជូនប្រជាជនតាមក្រុមមនុស្ស នៅរៀងរាល់ថ្ងៃ (ទាំងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកផ្លូវការ) ចាប់ពីម៉ោង ០៨:០០នាទីព្រឹក ដល់ម៉ោង ១៧:០០នាទីល្ងាច (ដោយសម្រាកពិសាអាហារថ្ងៃត្រង់ពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៤:០០នាទី)។

សម្រាប់ក្រុមមនុស្ស ដែលក្រសួងធ្លាប់បានចេញសេចក្តីជូនព័ត៌មានជាហូរហែចាប់តាំងពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ រួចមកហើយនោះ ហើយដែលមិនទាន់បានមកចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំង នៅតាមទីតាំងនានា ដែលក្រសួងធ្លាប់បានជូនព័ត៌មានរួចហើយ (មានដាក់ផ្សាយសេចក្តីជូនព័ត៌មាន តាមទំព័រហ្វេសបុករបស់ក្រសួងសុខាភិបាលរួចហើយ)។

ក្រសួង ក៏សូមក្រើនរំលឹកដល់អ្នកដែលបានចាក់វ៉ាក់សាំងលើកទី១ (ដូសទី១) រួចហើយ សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំងជាលើកទី២ (ដូសទី២) ក្នុងរយៈពេលពី ១៤ ទៅ ២៨ថ្ងៃ (មិនឱ្យលើសពី ២៨ថ្ងៃ) បន្ទាប់ពីថ្ងៃចាក់លើកទី១ នៅទីតាំងដែលសាមីជនបានចាក់លើកទី១ កុំបីអាក់ខានឡើយ។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជន ក្នុងក្រុមអាយុពី ១៨ ដល់ ៥៩ឆ្នាំ ផ្សេងៗទៀត នឹងអញ្ជើញមកទទួលវ៉ាក់សាំងកូវីដ-១៩ ដោយស្ម័គ្រចិត្តនាពេលក្រោយៗទៀត។

សូមបងប្អូនប្រជាពលរដ្ឋ ក្នុងក្រុមអាទិភាពផ្សេងៗទៀត ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ មេត្តាអធ្យាស្រ័យ ប្រសិនបើមិនទាន់ដល់វេនរបស់ខ្លួនទេនោះ សូមមេត្តារង់ចាំបន្តិចសិន ព្រោះនៅពេលនេះវ៉ាក់សាំងមានចំនួនកំណត់។

ថ្ងៃអាទិត្យ ០២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ម៉ម ប៊ុនហេង